ហេព្រើរ ជំពូកមួយ

ហើយដើម្បីផ្តល់—តិចតួច...ខ្ញុំគិតថាគ្មានអ្វីល្អសម្រាប់ខ្ញុំជាងព្រះបន្ទូលនោះទេ។ "សេចក្តីជំនឿកើតឡើងដោយការស្តាប់ឮ ហើយឮព្រះបន្ទូលរបស់ព្រះ។"

2 នៅថ្ងៃពុធ និងប្រហែលជាថ្ងៃអាទិត្យ កម្មវិធីមួយនៃថ្ងៃអាទិត្យ ផ្តល់ឱ្យគ្រូគង្វាលនូវការសម្រាកបន្តិច ដែលគាត់សមនឹងទទួលបានវាខ្លាំងណាស់ ហើយគិតថាប្រហែលជាយើងគ្រាន់តែយកសៀវភៅនៅក្នុងព្រះគម្ពីរ។ យើងធ្លាប់ធ្វើបែបនោះហើយ ពេលខ្លះនៅលើវាពេញមួយឆ្នាំ។

3 ខ្ញុំចាំថាមានពេលមួយដែលយើងបាននៅមួយឆ្នាំពេញលើសៀវភៅវិវរណៈ។ ប៉ុន្តែ អ៊ូ ខ្ញុំអើយ រឿងដែលយើងបានរៀន ហើយវាអស្ចារ្យយ៉ាងណា! បន្ទាប់មក យើងបានត្រឡប់ទៅសៀវភៅដានីយ៉ែល ឬសៀវភៅលោកុប្បត្តិ ឬនិក្ខមនំ ហើយគ្រាន់តែយកវា ពីមួយជំពូកទៅមួយជំពូក ហើយវាបានតភ្ជាប់ព្រះគម្ពីរទាំងមូលជាមួយគ្នា។ អូ ខ្ញុំស្រឡាញ់ណាស់!

4 បន្តិចក្រោយមក យើងត្រូវតែទទួល...ប្រសិនបើព្រះអម្ចាស់បន្តប្រទានពរ ហើយយើងបន្តទៅមុខទៀត យើងនឹងចូលទៅក្នុងចំណុចជ្រៅពិតប្រាកដមួយចំនួននៅទីនេះ ជ្រៅពិតមែន។ ហើយយើងនឹងទៅពីកន្លែងមួយទៅកន្លែងមួយតាមរយៈបទគម្ពីរជាមួយវា។

5 ហើយខ្ញុំចូលចិត្តយកបទគម្ពីរប្រៀបធៀបជាមួយបទគម្ពីរ។ នោះជារបៀបដែលវាត្រូវតែអញ្ចឹង។ វាគ្រាន់តែជារូបភាពដ៏ស្រស់ស្អាតដ៏អស្ចារ្យមួយ។ ហើយនៅក្នុងសៀវភៅនេះដែលយើងកំពុងសិក្សា យើងនឹងចូលទៅ អូ សេចក្តីសង្គ្រោះ និងការព្យាបាលដ៏ទេវភាព និងការអស្ចារ្យ និងសេចក្តីមេត្តាករុណា។ ហើយ អូ អ្វីគ្រប់យ៉ាងមកក្នុងទីនេះ។

6 ហើយប្រហែលជាពេលខ្ញុំទៅកន្លែងដែលខ្ញុំត្រូវទៅប្រជុំ...ខ្ញុំមិនដែលដឹងថាពេលណាខ្ញុំនឹងទៅប្រជុំ ហៅឱ្យទៅប្រជុំ ព្រោះខ្ញុំមិនមានអ្វីកំណត់រហូតដល់ខ្ញុំមានអារម្មណ៍ថាត្រូវធ្វើរឿងមួយជាក់លាក់។ ហើយនោះប្រហែលជានៅព្រឹកព្រលឹម ខ្ញុំប្រហែលជាហោះហើរទៅកាន់រដ្ឋកាលីហ្វ័រញ៉ា រហូតដល់រដ្ឋម៉ែនឬកន្លែងណាមួយ

ដែលទ្រង់នឹងហៅខ្ញុំ។ នោះហើយជាមូលហេតុដែលខ្ញុំមិនកំណត់ផ្លូវធំ ដំណើរ វែងឆ្ងាយ ព្រោះខ្ញុំមិនអាចធ្វើវាបាន។ កិច្ចការរបស់ខ្ញុំមិនត្រូវបានកាត់ចេញបែប នោះទេ ហើយវាគ្រាន់តែខុសគ្នា។

7 ហើយឥឡូវខ្ញុំមកផ្ទះដើម្បីសម្រាកបន្តិច។ ខ្ញុំបានស្រែកទម្ងន់ម្តៃជោន ក្នុង ជំនួបចុងក្រោយនេះ។ ហើយបងប្រុស មើស៊ីនិងបងប្រុសហ្គោដបានក្រោកឡើង មួយរយៈមុន ហើយបាននិយាយថា "បងប្រុសប្រាណាហាំ ខ្ញុំកត់សម្គាល់អ្វីដែល អ្នកធ្វើ។ អ្នកដាក់បេះដូងរបស់អ្នកទាំងស្រុង។"

8 ខ្ញុំបាននិយាយថា "នោះជាវិធីតែមួយគត់ដែលអ្នកអាចធ្វើការងារដ៏ត្រឹមត្រូវ មួយសម្រាប់ព្រះអម្ចាស់ អ្វីៗទាំងអស់ដែលអ្នកទទួលបានត្រូវនៅជួរមុខសម្រាប់ ព្រះគ្រីស្ទ អស់ពីកម្លាំងចិត្ត អស់ពីព្រលឹង អស់ពីបេះដូង អស់ពីគំនិត អ្វីៗដែល អ្នកមាន។" ពេលអ្នកធ្វើអ្វីក៏ដោយ ធ្វើវាឱ្យបានត្រឹមត្រូវ មិនអញ្ចឹងទេគឺកុំធ្វើអ្វី ទាល់តែសោះ សូមទុកវាចោល។ បើអ្នកនឹងក្លាយជាគ្រីស្ទាន ចូរដាក់អ្វីគ្រប់យ៉ាង ដែលអ្នកមានចំពោះព្រះគ្រីស្ទ នោះហើយ ជាពេលវេលារបស់អ្នក ទេពកោសល្យ របស់អ្នក អ្វីគ្រប់យ៉ាងរបស់អ្នក។

9 ខ្ញុំគ្រាន់តែកត់សម្គាល់ឃុវជនម្នាក់នេះ។ បងប្រុស បឺន នោះជាប្រពន្ធរបស់ អ្នក តើមែនទេ ដែលលេងនិងច្រៀងនៅទីនោះ គួស្នេហ៍វ័យក្មេងនោះ។ ហើយ —ហើយវាមិនមែនជាព្យាណូទេ វាក៏មិនមែនជាអ័កហ្គានដែរ ប៉ុន្តែវាជាឧបករណ៍ តន្ត្រីខ្លះ ពួកគេយកវាមកចងហើយបិត ហើយធ្វើអ្វីមួយថ្វាយព្រះ អម្ចាស់។ ប្រហែលជាអ្នកអាចធ្វើវា ហើយច្រៀង នោះគឺ ការយកឈ្នះព្រលឹង។ ធ្វើអ្វីមួយ មិនថារឿងអ្វីទេ។ ប្រសិនបើអ្នក—អ្នកអាចផ្លុំកហ្វៃ មែនហើយ ផ្លុំវាចុះ។ គ្រាន់តែ ធ្វើអ្វីមួយ។ គ្រាន់តែថ្លែងទីបន្ទាល់ ឬធ្វើអ្វីមួយសម្រាប់អាណាចក្ររបស់ព្រះ។ អ្វីក៏ដោយដែលអ្នកមាន ចូរដាក់វាទៅប្រើប្រាស់ក្នុងកម្មវិធីរបស់ព្រះ។

10 ឥឡូវនេះ យើងនឹងមិនព្យាយាមនៅយូរពេកទេ ព្រោះខ្ញុំដឹងថាអ្នកធ្វើការ។ អ្នកត្រូវក្រោកពីព្រលឹម។ ហើយខ្ញុំទៅបរបាញ់សត្វកំប្រុកជារឿងរាល់ព្រឹក។ ខ្ញុំ គ្រាន់តែប្រាប់អ្នកពីការពិត។ នោះហើយជាអ្វីដែលខ្ញុំកំពុងធ្វើ។ នោះហើយជាអ្វី ដែលខ្ញុំត្រូវមកផ្ទះ គឺដើម្បីសម្រាកបន្តិច។ ដូច្នេះហើយខ្ញុំក្រោកពីដំណេក ប្រហែល ម៉ោងបួន ហើយចេញទៅក្រៅក្នុងព្រៃ មែនហើយ ហើយដើរលេងបន្តិចហើយ ចូលគេង។ ហើយខ្ញុំកំពុងឡើងទម្ងន់មួយចំនួនមកវិញ ដូច្នេះខ្ញុំនឹងបានសម្រាក

បន្តិច ក្រោយមក ប្រសិនបើអ្នក...បើព្រះអម្ចាស់សព្វព្រះហឫទ័យ។ ហើយអ្វីៗគឺល្អ។

11 តោះ ឥឡូវនេះ យើងនឹងបើកព្រះគម្ពីររបស់អ្នក។ ខ្ញុំចង់ឱ្យអ្នកនាំយកព្រះគម្ពីរ
របស់អ្នករាល់យប់...តាមដែលអ្នកអាចធ្វើបាន។ បើមានអ្នកណាខ្លះខ្វះ ឬន
រណាម្នាក់ចង់អានតាមជាមួយនឹងគ្នាយើងមានគម្ពីរខ្លះនៅទីនេះ យើងនឹងមាន...
អ្នកដឹកនាំខ្លះដើម្បីហុចពួកគេចេញទៅឱ្យអ្នក។ មានអ្នកណាចង់បានមួយទេ?
មែនហើយ គ្រាន់តែលើកដៃរបស់អ្នកឡើង។

12 ឆ្ងល់ថាបើបងប្រុស...ដុក មកទីនេះហើយយកព្រះគម្ពីរទាំងនេះ។ អ្នកកំពុង
ឈរក្បែរនោះ ហើយបងប្រុសបឺន។ តើត្រូវទេ បឺន? ខ្ញុំបានលឺគាត់និយាយ...
[បងប្រុសនិយាយថា "ឧនរ៉ាដ។"—អេដ។] ថាម៉េច? ["ឧនរ៉ាដ។"] ឧនរ៉ាដ។ ខ្ញុំបាន
ហៅគាត់...ខ្ញុំពិបាកស្តាប់ណាស់ ប្រហែលជា បងប្រុសនេវីល។ តើខ្ញុំធ្លាប់បានដាក់
ឈ្មោះថាបឺនដោយរបៀបណា? ខ្ញុំស្គាល់មុខបុរសនោះ ហើយខ្ញុំមិនអាច ចាំឈ្មោះ
គាត់បានទេ។

13 ហើយអ្នកដឹងទេ ពេលអ្នកកាន់តែចាស់ទៅបន្តិច ខ្ញុំរកឃើញរឿងមួយ វា
កាន់តែពិបាកសម្រាប់ខ្ញុំក្នុងការអានព្រះគម្ពីរនេះ។ ហើយខ្ញុំគ្រាន់តែមិនចូលចិត្ត
គិតថាត្រូវពាក់វ៉ែនតា ដើម្បីអានគម្ពីរ។

14 ប៉ុន្តែ នៅទីនេះមិនយូរប៉ុន្មាន ខ្ញុំគិតថាខ្ញុំនឹងងងឹតភ្នែក។ ហើយខ្ញុំបានទៅមើល
សេម។ ហើយសេមបាននិយាយថា "ប៊ីល ខ្ញុំមិនដឹងទេ។" បាននិយាយថា "ខ្ញុំនឹង
ណាត់ឱ្យអ្នកជួបជាមួយអ្នកឯកទេស។"

15 ខ្ញុំបានទៅល្ងីសល្ងើល។ វាត្រូវតែជាឆន្ទៈរបស់ព្រះអម្ចាស់។ អ្នកឯកទេសល្អីៗ
មួយចំនួន ខ្ញុំភ្លេចឈ្មោះរបស់គាត់ហើយឥឡូវនេះ។ ប៉ុន្តែគាត់បានអានសៀវភៅ
របស់ខ្ញុំ។ ហើយគាត់បាននិយាយថា "ប្រសិនបើអ្នកបានត្រលប់ទៅអាហ្វ្រិកវិញ ខ្ញុំ
ចង់ទៅជាមួយអ្នក។" គាត់បាននិយាយថា "ហើយប្រសិនបើអ្នក...ពួកគេជនជាតិ
អាហ្វ្រិកស្រឡាញ់អ្នក។" ហើយបាននិយាយថា "ពួកគេមានជំនឿខ្លាំងណាស់
ជាពិសេសជាមួយការកាន់កាំបិត ដើម្បីទៅកាប់។ ដូច្នេះ" បាននិយាយថា "ខ្ញុំចង់
មានរយៈពេលប្រាំមួយខែនៃជីវិតរបស់ខ្ញុំ សម្រាប់ការវះកាត់ជំងឺភ្នែកឡើងបាយនិង
វត្ថុផ្សេងៗ នៅ...ក្នុងបេសកកម្ម។" ហើយបាននិយាយថា "ប្រសិនបើយើងអាច
ទៅជាមួយគ្នា ហើយអ្នកអាចឈ្នះការពេញចិត្តពីពួកគេ ដូចជា" បាននិយាយថា

"ចុះបើពួកគេមានជំងឺភ្នែកឡើងបាយនិងការងារភ្នែក" បន្តថា "ខ្ញុំគ្រាន់តែចង់ផ្តល់ឱ្យវា ដោយមិនគិតថ្លៃ ប្រាំមួយខែ។" ហើយខ្ញុំភ្លេចថាអ្នកត្រូវរង់ចាំការណាត់ជួបជាមួយគាត់រយៈពេលប៉ុន្មាន។

16 ហើយយើងកំពុងអង្គុយក្នុងបន្ទប់តូចមួយហើយវាមាន—ពន្លឺក្រហមតូចបន្តិចបើកមក នៅក្នុងបន្ទប់ងងឹតខាងក្រោយនោះ។ ហេតុអ្វី ខ្ញុំអាចអានអក្សរទាំងនោះបាន។ វាបាននិយាយថាម្តេ-ម្តេ។ ខ្ញុំអាចអានវាតាមវិធីណាមួយ។ ហើយគាត់បានពង្រីកវានៅដប់ប្រាំ-ដប់ប្រាំ ហើយខ្ញុំអាចអានវាបាន។ ហើយដាក់វានៅលើដប់-ដប់ ហើយខ្ញុំអាចអានវាបាន។ គាត់បាននិយាយថា "ជាការប្រសើរណាស់ មិនមានអ្វីខុសច្រើនចំពោះភ្នែករបស់អ្នកទេ។"

17 ដូច្នេះគាត់មានកែវយឺតតូចមួយ។ គាត់ដាក់ឧបករណ៍តូចមួយនៅក្រោយទីនោះ របស់តូចមួយ អ្នកដឹងទេ។ តេឡេស្កុបចាស់ៗ មានប៉ុន្មាននាក់ដែលនៅចាំ? យើងធ្លាប់មើលតាមរបស់នោះ មើលរូបភាព អ៊ីចឹងឯង។ ហើយគាត់បាននិយាយថា "តើអ្នកអាចអានវាបានទេ?"

ខ្ញុំបាននិយាយថា "បាទ បាន។"

គាត់បាននិយាយថា "អានវាឱ្យខ្ញុំ។"

18 វាមាន អូ កថាខណ្ឌទាំងមូល ប្រហែល*ដូចនោះ*។ ខ្ញុំចាប់ផ្តើម អានវា គាត់ចាប់ផ្តើមទាញវាឡើង *ដូចនោះ* កាន់តែយឺតទៅៗ។ គាត់ចូលដល់*បែបនេះ* ខ្ញុំឈប់។ គាត់បាននិយាយថា "ខ្ញុំអាចប្រាប់អ្នករឿងមួយថា អ្នកមានអាយុសែសិបហើយ។"

ខ្ញុំបាននិយាយថា "បាទ ត្រូវហើយ ផ្លូវឆ្លងកាត់ដ៏វែងឆ្ងាយ។"

19 គាត់បាននិយាយថា "តើអ្នកបានធ្វើវាដោយរបៀបណា?" គាត់បាននិយាយថា "ធម្មជាតិ ភ្នែកមនុស្ស នៅពេលដែលអ្នកមានអាយុសែសិបឆ្នាំ ដូចជាសក់របស់អ្នកក្លាយទៅជាពណ៌ប្រផេះ ជាដើម គ្រាប់ភ្នែកប្រែជាសំប៉ែត។" បាននិយាយថា "ឥឡូវនេះ ប្រសិនបើអ្នករស់នៅបានយូរគ្រប់គ្រាន់ នោះនឹងក្លឹតត្រលប់មកវិញម្តងទៀត" គាត់បាននិយាយថា "ការមើលឃើញទីពីរនោះ គេហៅវា។ ប៉ុន្តែ" បាននិយាយថា "មនុស្សដែលមានអាយុប្រហែលសែសិបឆ្នាំ ជាការពិត..." បាននិយាយថា "មិនមានបញ្ហាអ្វីជាមួយភ្នែករបស់ពួកគេទេ។"

20 ខ្ញុំអាច—ខ្ញុំអាចមើលឃើញសក់មួយបើវាជ្រុះលើឥដ្ឋ អាចដកវាចេញពីខ្ញុំ។ ប៉ុន្តែចូលទៅជិតខ្ញុំ...ហើយគាត់បាននិយាយថា "ឥឡូវនេះ អ្នកអានព្រះគម្ពីររបស់អ្នក" បាននិយាយថា "អ្នករុញវាឱ្យឆ្ងាយពីអ្នក។" បាននិយាយថា "ឃ្លេៀងទៅ ដៃរបស់អ្នកនឹងមិនវែងគ្រប់គ្រាន់ទេ រហូតដល់អ្នកមិនអាច—មិនអាចយកវាចេញពីទីនោះឆ្ងាយគ្រប់គ្រាន់ដើម្បីចាប់វាបានទេ។"

21 ដូច្នេះហើយគាត់បានធ្វើវែនតាឱ្យខ្ញុំមួយគូរ ហើយផ្នែកខាងក្រោមដែលអ្នកអាចមើលបាន គឺសម្រាប់អាន។ គាត់បាននិយាយថា "ឥឡូវនេះ នៅក្នុងវេទិការបស់អ្នក..." គាត់គិតថាខ្ញុំជាគ្រូអធិប្បាយដ៏ថ្លៃថ្នូរនៅទីនេះម្នាក់ អ្នកដឹងទេ។ ហើយដូច្នេះបាននិយាយថា...អ្នក...ផ្នែកខាងលើគ្រាន់តែជាកញ្ចក់បង្អួចធម្មតា កញ្ចក់ធម្មតាប៉ុណ្ណោះ។ ហើយផ្នែកខាងក្រោមមានប្រភេទកែវខ្លះៗនៅក្នុងវា ដែលខ្ញុំអាចអានវាជិតៗ អ្នកដឹងទេ *ដូចរនាះ*។ ដូច្នេះខ្ញុំគ្រាន់តែមិនចូលចិត្តពាក់ពួកគេទេ ពិតមែនហើយ។

22 ហើយឥឡូវនេះ នៅក្នុងការបង្រៀនព្រះគម្ពីរ ហើយខ្ញុំបានចូលដល់គម្ពីរសញ្ញាថ្មីនៅយប់នេះ។ ដូច្នេះហើយ...ខ្ញុំទទួលបានគម្ពីរសញ្ញាថ្មីរបស់ខ្លួនហើយវាត្រូវបានបោះពុម្ពនូវទំហំល្អ។ ប៉ុន្តែឥឡូវនេះ ពេលដែលខ្ញុំចូលទៅក្នុងមួយផ្សេងទៀត ខ្ញុំ—ខ្ញុំប្រហែលជាត្រូវទៅរកគម្ពីរជាមិត្តចាស់—និងប្រភេទនៃការអានតាមរយៈពួកគេ។ ប៉ុន្តែទោះអ្វីក៏ដោយ ខ្ញុំ—ខ្ញុំរីករាយដែលខ្ញុំបានអ្វីមួយខ្ញុំ—ខ្ញុំនៅតែអាចអានបាន។ ហើយ—និង—ហើយអ្វីដែលខ្ញុំទទួលបាន ខ្ញុំនឹងផ្តល់ឱ្យអ្នកគ្រប់គ្នានូវអ្វីគ្រប់យ៉ាងដែលខ្ញុំអាចធ្វើបាន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ សង្ឃឹមថាទ្រង់នឹងដកសញ្ញានៃអាយុនោះចេញ។ ខ្ញុំមិនអាចសុំទ្រង់ដកអាយុរបស់ខ្ញុំចេញទេ។ ខ្ញុំ...មែនហើយ នោះគ្រាន់តែជារឿងមួយដែលយើងទាំងអស់គ្នាត្រូវធ្វើ។ យើងត្រូវឆ្លងកាត់វា។ ហើយខ្ញុំដឹងថាខ្ញុំមិនមែនជាក្មេងតូចដូចពីមុនទេ គឺឈរនៅទីនេះនៅលើវេទិកា។ ខ្ញុំមានអាយុសែសិបប្រាំបីឆ្នាំ។ ហើយគិតទៅ ពីរឆ្នាំទៀតនឹងមានអាយុហាសិបឆ្នាំហើយ បងប្រុសមែ។

23 ខ្ញុំអើយ សឹងតែមិនជឿ! ខ្ញុំគ្រាន់តែ...ខ្ញុំមិនដែលដឹងថាខ្ញុំមានអាយុលើសម្ភៃឆ្នាំទេរហូតប្រហែលពីរឆ្នាំមុននេះ។ ត្រូវហើយ។ ត្រូវហើយ។ ខ្ញុំគ្រាន់តែ...ខ្ញុំមិនអាចជឿវាបានទេ។ ហើយនៅឡើយខ្ញុំ—ខ្ញុំ...វាពិបាកសម្រាប់ខ្ញុំក្នុងការជឿរហូតដល់មើលក្នុងកញ្ចក់ ហើយបន្ទាប់មកខ្ញុំ—ខ្ញុំដឹងថាវាគឺពិតមែន ហ្នឹងហើយ។

ប៉ុន្តែ—ប៉ុន្តែគ្រាន់តែសម្លឹងមើល ខ្ញុំគ្រាន់តែមានអារម្មណ៍ល្អដូចដែលខ្ញុំធ្លាប់មានអារម្មណ៍ក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំក៏អរគុណចំពោះរឿងនោះដែរ។ សរសើរតម្កើងព្រះជាម្ចាស់។

24 ឥឡូវនេះ យើងកំពុងសិក្សាគម្ពីរហេព្រើរ។ វាបាន...អូ វាជាសៀវភៅមួយក្នុងចំណោមសៀវភៅដ៏ជ្រៅបំផុត និងមានបំផុតនៃព្រះគម្ពីរ។ ខ្ញុំប្រាប់អ្នកថា វាជាសៀវភៅដែលពិតជានឹង...ប្រសិនបើព្រះជាម្ចាស់អនុញ្ញាត ហើយយើងគ្រាន់តែចុះទៅក្នុងរឿងនេះ ខ្ញុំជឿថា យើងនឹងរកឃើញដុំមាសរហូតដល់យើងស្រែកសរសើរព្រះគ្រប់ពេល។ ហើយឥឡូវនេះខ្ញុំ...

25 សៀវភៅហេព្រើរ គឺពិតជាហ្នឹងហើលយ វាត្រូវបានសន្មត់បានសរសេរដោយសាវកប៉ុល ខ្ញុំគិតថាជាអ្នកបង្ហាញព្រះគម្ពីរដ៏ធំបំផុត ដែលពិភពលោកមិនធ្លាប់មាន នៅក្រៅពីព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង។ ហើយប៉ុលបានបំបែក...ឥឡូវនេះ ប៉ុលគឺជាគ្រូបង្រៀនព្រះគម្ពីរពិតប្រាកដម្នាក់ នោះគឺ គម្ពីរសញ្ញាចាស់។ នោះគឺជាសៀវភៅតែមួយគត់ដែលត្រូវបានសរសេរនៅពេលនោះ ហៅថាព្រះគម្ពីរ។ ហើយគាត់បានព្យាយាមបង្ហាញដល់សាសន៍ហេព្រើរ ការបំបែកគម្ពីរសញ្ញាចាស់និងបង្ហាញសញ្ញាចាស់ថាជាស្រមោលឬវាចង្អុលទៅគម្ពីរសញ្ញាថ្មី។

26 នៅទីនោះយើងអាចវាយខ្សែបណ្តាញផ្ទះមួយហើយស្នាក់នៅទីនោះបីខែតាមការគិត នៅទីនោះ។ ដើម្បីត្រឡប់ទៅវិញភ្លាម ប្រសិនបើយើងអាចបើកព្រះគម្ពីររបស់យើងឥឡូវនេះ ពិតណាស់ យើងនៅលើហេព្រើរ ជំពូកទី១។ ប៉ុន្តែប្រសិនបើយើងងាកទៅរកវិវរណៈ ជំពូកទី១២ នោះអ្នកនឹងឃើញវាយ៉ាងល្អឥតខ្ចោះម្តងទៀត របៀបដែលជាស្រមោល។ ប្រសិនបើ...អ្នកដែលមានខ្មៅដៃដែលត្រៀមកត់ត្រាបទគម្ពីរ។ នៅហេ-...

27 នៅក្នុង វិវរណៈ១១ យើងរកឃើញថា យ៉ូហាន នៅលើកោះប៉ាត់ម៉ុសបានឃើញស្ត្រីម្នាក់ឈរនៅលើមេឃ នាងមានព្រះអាទិត្យនៅក្បាលរបស់នាង ហើយព្រះច័ន្ទនៅក្រោមជើងរបស់នាង។ ស្ត្រីនោះត្រូវរងគ្រោះ ដោយមានកូននឹងត្រូវកើត។ នាងបានបង្កើតកូនប្រុសម្នាក់។ នាគក្រហមឈរ លេបត្របាក់កូនភ្លាមៗពេលកើតមកនោះ។ ហើយ—កូននោះត្រូវបានចាប់ឡើងទៅស្ថានសួគ៌ ហើយស្ត្រីនោះបានរត់ទៅក្នុងទីរហោស្ថាន ដែលជាកន្លែងនាងត្រូវបានចិញ្ចឹម

សម្រាប់ ពេលវេលាមួយ និងពេលវេលាពាក់កណ្តាល ឬការបែងចែកពេលវេលា។

28 ឥឡូវនេះ ស្ត្រីនោះតំណាងឲ្យក្រុមជំនុំ ហើយកូនដែលនាងបានបង្កើតមកគឺ ព្រះគ្រីស្ទ។ ព្រះច័ន្ទនៅក្រោមជើងរបស់នាងគឺជាច្បាប់ ព្រះអាទិត្យនៅក្បាលរបស់ នាងគឺព្រះគុណ។ ផ្កាយដប់ពីរនៅក្នុងមកុដរបស់នាងគឺជាសាវ័កដប់ពីរនាក់។ ហើយនៅទីនោះ នៅឯណា...សាវ័កដប់ពីរនាក់គឺជាសិរីល្អឬជាការគ្រងមកុដនៃ គម្ពីរសញ្ញាថ្មី។ ឃើញទេ? "ព្រោះគ្មានគ្រឹះផ្សេងទៀតអាចត្រូវបានគេសង់លើជាង គ្រឹះដែលបានដាក់រួចហើយនោះទេ។" ឃើញទេ? វា គ្រឹះ គឺ—គម្ពីរសញ្ញាថ្មី ពួក សាវ័ក គោលលទ្ធិរបស់សាវ័ក ជាដើម គឺជាមកុដនៃព្រះគម្ពីរសញ្ញាថ្មី។ ហើយ បន្ទាប់មកនៅ...

29 ព្រះច័ន្ទគឺជាស្រមោលនៃព្រះអាទិត្យ។ ព្រះអាទិត្យគ្រាន់តែឆ្លុះបញ្ចាំងពន្លឺរបស់ វានៅពេលដែលវានៅពីក្រោយផែនដី។ ហើយព្រះច័ន្ទផ្តល់ពន្លឺ ឱ្យដើរ នៅពេល យប់។ ហើយអ្វីដែលជារូបភាពដ៏ស្រស់ស្អាតដែលយើងមាននៅទីនេះ រូបភាព ដ៏ស្រស់ស្អាតមួយផ្សេងទៀត: ព្រះអាទិត្យតំណាងឱ្យព្រះគ្រីស្ទ ហើយ—ព្រះច័ន្ទ តំណាងឱ្យក្រុមជំនុំ។ ពួកគេដូចជាប្តីប្រពន្ធ។ ហើយនៅក្នុងអវត្តមាននៃព្រះគ្រីស្ទ ក្រុមជំនុំបានឆ្លុះបញ្ចាំងពីពន្លឺតូចមួយ ដែលជាដំណឹងល្អ។ ហើយវា—វាជា ពន្លឺដែលដើរចូលរហូតដល់ព្រះរាជបុត្រារស់ឡើងវិញ បន្ទាប់មក ក្រុមជំនុំ និង ព្រះបុត្រា ព្រះច័ន្ទ និងព្រះអាទិត្យ បញ្ចូលគ្នា។ ឃើញទេ? ព្រះច័ន្ទគឺជាផ្នែកមួយ នៃព្រះអាទិត្យ ហើយក្រុមជំនុំគឺជាផ្នែកមួយនៃព្រះគ្រីស្ទ។ ហើយខណៈពេលដែល អវត្តមាននៃព្រះគ្រីស្ទ ក្រុមជំនុំឆ្លុះបញ្ចាំងពីពន្លឺរបស់ទ្រង់។ ហើយបន្ទាប់មក យើង អាចមើលឃើញព្រះច័ន្ទចាំងពន្លឺ វាដឹងថាព្រះអាទិត្យកំពុងរះនៅកន្លែងណាមួយ។ ហើយដរាបណាក្រុមជំនុំកំពុងឆ្លុះបញ្ចាំងពីពន្លឺនៃព្រះគ្រីស្ទ នោះព្រះគ្រីស្ទមាន ព្រះជន្មរស់នៅកន្លែងណាមួយ។ អាម៉ែន។ គិតពីការនេះ។

30 ឥឡូវនេះ ច្បាប់គឺជាប្រភេទនៃព្រះគុណមួយ ប៉ុន្តែច្បាប់មិនមានអំណាច សង្គ្រោះនៅក្នុងវាទេ។ ច្បាប់គ្រាន់តែជា...ច្បាប់គឺជាប៉ូលីស។ ប៉ូលិសដាក់អ្នកចូល គុក ប៉ុន្តែ អ្នកឃើញទេ ថាវាជាព្រះគុណក្នុងការយកអ្នកចេញពីគុក។ ឃើញទេ?

31 ដូច្នេះ ព្រះលោហិតរបស់ព្រះគ្រីស្ទ ជាដំណឹងល្អ រំដោះយើងពីអំពើបាប។ ច្បាប់ធ្វើឲ្យយើងមានបាបប៉ុណ្ណោះ។ ច្បាប់បានត្រឹមតែនិយាយថា "អ្នកគឺជាមនុស្ស មានបាប។ អ្នកមិនត្រូវលួចទេ។ អ្នកមិនត្រូវប្រព្រឹត្តអំពើផិតក្បត់ឡើយ។ អ្នកមិន

ត្រូវធ្វើជាសាក្សីក្លែងក្លាយឡើយ។" ឃើញទេ? វាជាប៉ូលិសដែលនិយាយថាអ្នកខុសហើយអ្នកមានទោស។ ប៉ុន្តែដំណឹងល្អគឺជាដំណឹងល្អ។ ព្រះគ្រីស្ទបានសុគតដើម្បីជួយសង្គ្រោះយើងពីរាល់ការរំលងរបស់យើង ការបំពានច្បាប់។ ព្រះគ្រីស្ទបានសុគតដើម្បីយកយើងចេញ។

32 ឥឡូវនេះ ប៉ុល ដរាបណាគាត់បានប្រែចិត្ត គាត់មិនដែលពិគ្រោះជាមួយថ្នាក់សិក្ខាសាលាណាមួយឡើយ គាត់ក៏មិនបានពិគ្រោះជាមួយអ្នកដឹកនាំណាម្នាក់ដែរ។ ប៉ុន្តែតើអ្នកបានកត់សម្គាល់ទេ? គាត់បានចុះទៅក្នុងប្រទេសអារ៉ាប់ ហើយនៅទីនោះបីឆ្នាំនៅក្នុងប្រទេសអារ៉ាប់។ ឥឡូវនេះ នេះជា តាមគំនិតរបស់ខ្ញុំ គឺថា...

33 ឥឡូវនេះ យើងត្រូវតែមានសាវតានៃរឿងនេះ ដូច្នេះយើងនឹងដឹងថាវាមានសារៈសំខាន់ប៉ុណ្ណា។ ហើយមេរៀនទីមួយ យប់នេះ យើងសិក្សាពីប្រវត្តិ។

34 ឥឡូវនេះ ប៉ុលគឺជាគ្រូបង្រៀនគម្ពីរម្នាក់ ពីព្រោះគាត់ត្រូវបានបង្រៀនក្រោមកាម៉ាលៀល គ្រូដ៏ល្បីគ្រប់សម័យកាលនោះ។ ហើយគាត់ជាអ្នកល្បីបំផុតនៅសម័យនោះ គឺជាគ្រូច្បាប់ដ៏អស្ចារ្យ និងជាហោរា។ ដូច្នេះ ប៉ុលបានរៀនពូកែក្នុងរឿងទាំងនោះ។

35 ហើយបន្ទាប់មកខ្ញុំចូលចិត្តគាត់តាមរបៀបនេះ ការបើកសម្តែងដ៏អស្ចារ្យនេះមានភាពស្មោះត្រង់ក្នុងចិត្តរបស់គាត់ ជាឃាតក គាត់បានយល់ព្រមចំពោះការស្លាប់របស់ស្តេផាន ហើយបានឃើញស្តេផានស្លាប់នៅក្រោមផ្ទាំងថ្ម និងដុំថ្មនៃការត្រូវគប់រហូតដល់ស្លាប់។ ខ្ញុំគិតថាវាច្បាស់ជាបានទៅជិតប៉ុលពេលគាត់ឃើញស្តេផានលើកដៃទៅស្ថានសួគ៌ ហើយនិយាយថា "ខ្ញុំឃើញស្ថានសួគ៌បើកចំហរ។ ខ្ញុំឃើញព្រះយេស៊ូវឈរនៅខាងស្តាំដៃរបស់ព្រះ។" ហើយគាត់បាននិយាយថា "ព្រះបិតាអើយ កុំដាក់ទោសអំពើបាបនេះប្រឆាំងនឹងពួកគេ។" ហើយគាត់បានដេកលក់ទៅ។

36 តើអ្នកបានកត់សម្គាល់ទេ? គាត់មិនដែលស្លាប់ទេ។ គាត់បានដេកលក់។ ដូច...ខ្ញុំមិនជឿថាគាត់ធ្លាប់មានអារម្មណ៍ឈឺចំពោះថ្មផ្សេងទៀតទេ។ ដូចទារកនៅលើច្រូងម្តាយ ដេកលក់ ស្តេផានបានដេកលក់នៅក្នុងព្រះហស្តរបស់ព្រះ។

37 មានអ្វីមួយអំពីប៉ុលដែលនៅជិតគាត់។ បន្ទាប់មក គាត់ជាបុរសម្នាក់ដែលស្ថិតនៅក្រោមការផ្តន្ទាទោស ព្យាយាមប្រយុទ្ធប្រឆាំងនឹងវា គាត់បានវិលទៅ

រកសម្តេចសង្ឃ ហើយទទួលបានសំបុត្រមួយចំនួន។ បាននិយាយថា "ខ្ញុំ នឹងចាប់មនុស្សទាំងអស់ដែលធ្វើឱ្យមានការរំខានទាំងអស់នោះ និងពួកអ្នក ខុសឆ្គងទាំងនោះ" ដែលត្រូវបានចាត់ទុកថាជាអ្វីដែលយើងនឹងហៅនៅថ្ងៃនេះថា "ពួកនិយមជ្រុល" ឬអ្វីមួយដូចនោះ បង្កើតសំឡេងរំខានច្រើន និងបង្កការរំខាន។ "យើងនឹងចុះទៅដោះស្រាយវា។"

38 ហើយនៅលើផ្លូវរបស់គាត់ គឺផ្លូវចាស់បន្តិច...មិនមែនជាផ្លូវធំដូចយើង ធ្វើដំណើរនោះទេ។ ហើយផ្លូវទាំងនោះនៅប៉ាឡេស្ទីន គ្រាន់តែជាផ្លូវតូចៗ ដូចជា ផ្លូវគោឆ្លងកាត់ព្រៃដែលគោក្របីដើរ ហ្វូងចៀម សេះ លា និងអូដ្ឋ បានដើរលើភ្នំ។

39 ហើយប៉ុល នៅតាមផ្លូវចុះទៅក្រុងដាម៉ាស ប្រហែលថ្ងៃត្រង់ នៅថ្ងៃមួយ ពន្លឺដ៏ អស្ចារ្យមួយបានរះចុះមកដល់ដី។ គ្មាននរណាម្នាក់បានឃើញវាទេ ក្រៅពីប៉ុល។ ខ្ញុំ ចង់ឱ្យអ្នកកត់សម្គាល់វា។ ហើយនៅទីនេះ វាមិនមែនជារឿងផ្ទាល់ខ្លួនទេឥឡូវនេះ ប៉ុន្តែគ្រាន់តែដូច្នេះយើងកំពុងឈានទៅរកប្រវត្តខាងក្រោយនេះ។ ថាអ្នកនឹងដឹងថា ព្រះយេស៊ូវគឺនៅដដែលនោះ...

40 ឥឡូវនេះ នៅពេលដែលទ្រង់គង់នៅលើផែនដី ទ្រង់មានបន្ទូលថា "ខ្ញុំមកពី ព្រះ ហើយខ្ញុំត្រឡប់ទៅឯព្រះវិញ។"

41 ឥឡូវនេះ នៅពេលដែលទ្រង់បានដឹកនាំកូនចៅអ៊ីស្រាអែល ទ្រង់គឺជាបង្គោល ភ្លើង។ ហើយទ្រង់បានក្លាយជាសាច់ឈាម រួចទ្រង់បានត្រឡប់ទៅបង្គោលភ្លើង ដដែលនោះវិញ។ ហើយនៅពេលដែលទ្រង់បានជួបប៉ុលនៅលើផ្លូវទៅកាន់ក្រុងដា ម៉ាស ទ្រង់គឺជាបង្គោលភ្លើង ដែលជាពន្លឺនោះ ឃើញទេ ជាពន្លឺដ៏អស្ចារ្យ។ ហើយ ប៉ុលបាននិយាយថា "តើខ្ញុំបានបៀតបៀនអ្នកណា?"

42 គាត់បាននិយាយថា "ខ្ញុំជាព្រះយេស៊ូវដែលអ្នកបៀតបៀននោះ" ជាពន្លឺ។ អូ តើទ្រង់មិនអស្ចារ្យទេឬ?

43 ហើយទ្រង់គង់នៅ យប់នេះ នៅទីនេះជាមួយយើង។ តើរូបភាពរបស់ទ្រង់បាន ឋិតនៅទីនោះ រឿងដូចគ្នា ឃើញទេ បង្គោលភ្លើង ពន្លឺ ដូចគ្នានឹងទ្រង់ដែរ "ដូចគ្នា កាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។"

44 ឥឡូវនេះ បុរសដែលនៅជាមួយគាត់មិនបានឃើញពន្លឺនោះទេ ប៉ុន្តែវានៅ ទីនោះដូចគ្នា។ លទ្ធផលផ្តល់ឱ្យដូចគ្នា។

45 ឥឡូវនេះ តើវាអាចទៅរួចដែរឬទេ—តើមាននរណាម្នាក់អាចឃើញព្រះគ្រីស្ទ នៅក្នុងអគារនេះហើយគ្មាននរណាម្នាក់ឃើញទ្រង់ទេ? ប្រាកដណាស់។ វាបានកើតឡើងនៅទីនោះ។

46 វាក៏បានកើតឡើងនៅយប់មួយនៅពេលដែលពេត្រុសកំពុងជាប់គុក។ ហើយពន្លឺនោះបានចូលមកក្នុងគុក ហើយពាល់ពេត្រុស ហើយដើរត្រង់ក្បែរអ្នកយាមខាងក្នុង អ្នកយាមខាងក្រៅ ដើរតាមទ្វារ ទ្វារធំ និងទ្វារទីក្រុង។ ពេត្រុសបាននិយាយថា "ខ្ញុំច្បាស់ជាសុបិនហើយ។" ប៉ុន្តែគាត់បានក្រឡេកមើលជុំវិញ ប៉ុន្តែពន្លឺបានរលត់ទៅ ព្រះគ្រីស្ទ ជាពន្លឺដ៏អស់កល្ប ជានិរន្តរ៍។ ទ្រង់នៅទីនោះ។ ឥឡូវនេះនៅលើតាមផ្លូវចុះមក...

47 ហើយមើលរឿងមួយទៀត ប្រសិនបើយើងនឹងនិយាយអំពីរឿងនេះ សូមគិតក្នុងចិត្តរបស់ខ្ញុំ។ ប៉ុន្តែអ្នកប្រាជ្ញដែលដើរតាមតារា តាំងពីប្រទេសឥណ្ឌាទិសខាងកើត រាប់ខែ មកតាមជ្រលងភ្នំនិងវាលខ្សាច់ (ឆ្លងកាត់កន្លែងសង្កេត ហើយពួកគេបានរក្សាពេលវេលានៃយប់ដោយផ្កាយ) ហើយគ្មានអ្នកប្រវត្តិសាស្ត្រ ឬអ្នកណានិយាយថាធ្លាប់ឃើញផ្កាយនោះទេប៉ុន្តែអ្នកប្រាជ្ញបានឃើញ។ វាគ្រាន់តែមានន័យសម្រាប់ពួកគេដើម្បីមើលវា។

48 ដូច្នេះ អ្នកអាចមើលឃើញអ្វីដែលអ្នកដទៃប្រហែលជាមិនបានឃើញ។ សម្រាប់អ្នក វាជាការពិត។ ចំពោះគាត់ ពួកគេមិនយល់ទេ។ គ្រាន់តែដូចជាការបម្លែងមួយ អ្នកអាចត្រូវបានប្រែចិត្តជឿ ហើយរីករាយនឹងពរជ័យនៃព្រះ គ្រាន់តែ—គ្រាន់តែធឹកនៅក្នុងពរជ័យរបស់ព្រះ។ ហើយអ្នកបន្ទាប់អង្គុយក្បែរអ្នក "ខ្ញុំមិនឃើញអ្វីទេ។" ឃើញទេ? ឃើញទេ? នោះហើយ។ "ខ្ញុំគ្រាន់តែមិនយល់។ ខ្ញុំមិនឃើញថាវាមានអ្វីទាំងអស់។" មែនហើយ គាត់គ្រាន់តែមិនទទួលបានវា។ ហ្នឹងហើយ។ តើ អ្នកនៅឯណា។

49 សូមកត់សម្គាល់ឥឡូវនេះ ប៉ុលនៅលើផ្លូវរបស់គាត់ចុះទៅ។ ហើយភ្លាមៗនៅពេលដែលបទពិសោធន៍ដ៏អស្ចារ្យនេះបានកើតឡើងចំពោះគាត់...ឥឡូវនេះគាត់មិនពេញចិត្តទេ...នោះហើយជាអ្វីដែលធ្វើឱ្យប៉ុលល្អណាស់។

50 ឥឡូវនេះមេរៀនរបស់យើងយប់នេះមិនស៊ីជម្រៅទេ។ វាជាមេរៀនដ៏រាក់មួយ ប៉ុន្តែយើងនឹងចូលទៅកាន់ជម្រៅបន្ទាប់ពីពេលនោះ។ ប៉ុន្តែនេះគឺជាមេរៀន

ដ៏រាក់ទាក់ ប៉ុន្តែវាទើបតែចាប់ផ្តើម។ ហើយអ្វីដែលវាគឺ វាជារឿងមួយដែលលើកតម្កើងព្រះយេស៊ូវគ្រីស្ទ។ ប៉ុល ដើម្បីចាប់ផ្តើម។

51 ហើយមុននឹងគាត់ធ្វើដូច្នេះ ប៉ុលគឺជាអ្នកប្រាជ្ញព្រះគម្ពីរ។ ហើយអ្នកប្រាជ្ញព្រះគម្ពីរម្នាក់នឹងមិនដាក់គោលលទ្ធិរបស់គាត់លើបទពិសោធន៍ឡើយ។ អត់ទេបាទ។ ពួកគេនឹងមិនដាក់គោលលទ្ធិរបស់ពួកគេតាមបទពិសោធន៍ឡើយ។ អ្នកអាចមានបទពិសោធន៍ណាមួយ។ ប៉ុន្តែវាត្រូវតែជា**ព្រះបន្ទូលរបស់ព្រះអម្ចាស់។** ត្រូវហើយ។

52 ឥឡូវនេះ នៅក្នុងគម្ពីរសញ្ញាចាស់ ពួកគេមានវិធីបីផ្សេងគ្នាដែលពួកគេអាចដឹងពីសារមួយ។ ទីមួយ គឺច្បាប់ នោះគ្រាន់តែជាច្បាប់ប៉ុណ្ណោះ។ បន្ទាប់មក ពួកគេមាន ព្យា—ព្យាការី អ្នកសុបិន ហើយពួកគេមានយូរីមធូមមីម។ ឥឡូវនេះវាអាចជ្រៅបន្តិច។

53 យូរីមធូមីម គឺជាអាវបាំងដែលអើរ៉ុនពាក់លើទ្រូងរបស់គាត់។ នៅក្នុងនោះមានថ្មចំនួនដប់ពីរគឺៈសាមស៊ី បារកេត មណីជោតិជាដើម ចុះតាមហ្នឹង។ ពួកគេមានថ្មធំៗទាំងដប់ពីរ ដែលនៅក្នុងប្រដាប់ពាក់លើទ្រូង បង្ហាញថាគាត់ជាមហាបូជាចារ្យនៃគ្រប់កុលសម្ព័ន្ធ គឺកុលសម្ព័ន្ធទាំងដប់ពីររបស់អ៊ីស្រាអែល។ បន្ទះទ្រូងនេះព្យួរនៅលើសសរក្នុងព្រះវិហារ។ ហើយពេលដែលហោរាបានទាយ ហើយគេចង់ដឹងថាវាត្រូវ ឬក៏អត់ ហោរាឬអ្នកយល់សប្តិបានឈរនៅមុខយូរីមធូមីមនេះ ហើយគាត់ប្រាប់ពីសុបិន ឬការនិមិត្តរបស់គាត់ ទោះជាគាត់បានឃើញអ្វីក៏ដោយ។ ហើយប្រសិនបើពន្លឺពិសិដ្ឋ...អូ តើអ្នកឃើញទេ? ព្រះទ្រង់តែងតែគង់នៅក្នុងឋានអច្ឆរិយៈ។ ភាពកកកុញ ពន្លឺទាំងនោះ គឺជារឿងធម្មតា ទាល់តែសំឡេងនេះបន្លឺឡើង។ ហើយពេលដែលសំឡេងបុកថ្មទាំងនោះ បើវាមិនមែនជារឿងអព្ភូតហេតុទេ នាងបានដេកនៅស្ងៀម។ ប៉ុន្តែប្រសិនបើវាជារឿងអស្ចារ្យ នោះពន្លឺទាំងនោះបានឆ្លុះបញ្ចាំងពណ៌ឥន្ទធនូជាមួយគ្នា។ អាម៉ែន។ បន្ទាប់មក នោះគឺជាព្រះមានបន្ទូលថា "នោះគឺជាហោរារបស់ខ្ញុំ។" ឬ "សុបិននោះមកពីខ្ញុំ។" នេះបើតាមយូរីម ធូមីម ដែលគេវិនិច្ឆ័យ។

54 នៅចាំសូលពេលគាត់ឈប់ជឿបានទេ? គាត់បាននិយាយថាគាត់មិនអាចមានសុបិនបានទេ។ ហើយហោរា សាំយូអែល បានស្លាប់ ហើយគ្មានផ្លូវណាទេ។ គាត់បាននិយាយថា "សូម្បីតែយូរីមក៏មិននិយាយជាមួយខ្ញុំដែរ។" គ្មានអ្វី

សោះ។ សូលបានឈរនៅចំពោះមុខយ៉ូរីម ហើយពាក្យសម្តីរបស់គាត់បានបន្លឺឡើង។ ឃើញទេ? ព្រះគ្រាន់តែបដិសេធគាត់។ ហើយថាយ៉ូរីមធូមីម នោះជាការបើកសម្តែងរបស់អើរ៉ុនអំពីបព្វជិតភាពរបស់គាត់។ បន្ទាប់ពីអើរ៉ុនទៅ លោកម៉ូសេគឺ—ចានព្យួរនៅលើសសរ។

55 ឥឡូវនេះ បព្វជិតភាពអើរ៉ុនបានឈប់នៅពេលព្រះយេស៊ូវបានសុគត។ ហើយឥឡូវនេះ ការបំបែកច្បាប់ពីព្រះគុណ យើងនៅតែមាន យ៉ូរី ធូមីម។ ហើយប៉ុលកំពុងប្រើវា។ ឃើញទេ? យ៉ូរីមធូមីម សព្វថ្ងៃនេះគឺជាព្រះបន្ទូលដ៏អមតៈ ដ៏អស់កល្ប និងអស់កល្បជានិច្ចរបស់ព្រះ។ ឃើញទេ?

56 "ដ្បិតអ្នកណានឹងយកអ្វីមួយចេញពីគម្ពីរនេះ ឬបន្ថែមអ្វីទៅក្នុងគម្ពីរនោះ។" ខ្ញុំមិនចង់បានអ្វីក្រៅពីវា ប៉ុន្តែខ្ញុំចង់បានទាំងអស់ដែលវាមាន។ នោះជាក្រុមជំនុំដែលយើងចង់បាន។ ហើយអ្វីៗទាំងអស់ត្រូវតែបញ្ជាក់ដោយព្រះបន្ទូល។

57 នោះហើយជាមូលហេតុដែលខ្ញុំបានធ្លាក់ថ្មីៗនេះក្នុងចំណោមប្រជាជនពេនទីកុស្ត ពីព្រោះ និយាយថា "ខ្ញុំមិនអាចយល់ថាតើប្រែងចេញពីដៃអ្នកទៅណា ឬឈាមចេញពីមុខអ្នក គឺជាសញ្ញាមួយដែលអ្នកមានព្រះវិញ្ញាណបរិសុទ្ធ។" នោះមិនមែនជាបទគម្ពីរទេហើយខ្ញុំ—ខ្ញុំគ្រាន់តែមិនអាចយកវាបាន។ វាត្រូវតែមកពីព្រះបន្ទូល។

58 ហើយឥឡូវនេះ ប៉ុល គាត់គ្រាន់តែស្រឡាញ់ព្រះបន្ទូល។ ដូច្នេះ មុននឹងគាត់ធ្លាប់ឃើញបទពិសោធន៍ដ៏អស្ចារ្យនេះដែលគាត់មាន គាត់បានចុះទៅក្នុងប្រទេសអេហ្ស៊ីបអស់រយៈពេលបីឆ្នាំ។ ខ្ញុំជឿថាវាមានរយៈពេលបីឆ្នាំ បីឆ្នាំចុះនៅក្នុងប្រទេសអេហ្ស៊ីប។ ហើយអ្នកដឹងថាខ្ញុំជឿថាគាត់ធ្វើអ្វីទេ? ខ្ញុំជឿថាគាត់បានយកគម្ពីរសញ្ញាចាស់ ហើយស្វែងរកតាមរយៈគម្ពីរសញ្ញាចាស់ ហើយបានរកឃើញថា នោះគឺជាព្រះមេស្ស៊ីពិតប្រាកដ។ ទ្រង់ត្រូវតែបញ្ជាក់បទពិសោធន៍របស់ទ្រង់ដោយព្រះគម្ពីរ។ អាម៉ែន។ អូ ខ្ញុំអើយ!

59 មើលទៅគាត់ពេលគាត់ជាប់គុក។ អ្នកសម្គាល់ឃើញថា មានមួយ—កន្លែងមួយនៃជីវិតរបស់ប៉ុល នៅពេលដែលគាត់នៅក្នុងគុកនៅទីនោះអស់រយៈពេលជាយូរ។ គាត់បានសរសេរសៀវភៅអេភេសូរ។ គាត់បានសរសេរសំបុត្រហេព្រើរនេះ។ ឃើញទេ? គាត់មានពេល។ ព្រះបានដាក់គាត់នៅទីនោះក្នុងគុក ហើយគាត់បានសរសេរសំបុត្រទាំងនេះទៅកាន់ក្រុមជំនុំ។ មួយទៅក្រុមជំនុំអេភេសូរ។

គាត់បានសរសេរមួយទៅក្រុមជំនុំពេនទីកុស្ត មានបញ្ហាជាច្រើនជាមួយពួកគេ។ ក្រុមជំនុំពេនទីកុស្តគាត់មានបញ្ហាច្រើនជាងអ្នកដទៃទៀត។ នៅតែមាន។ ប៉ុន្តែគាត់បានដឹងគុណចំពោះពួកគេ។ រឿងតែមួយគត់ដែលគាត់អាចបង្រៀនពួកគេ... នៅពេលពួកគេចូលមក៖ មួយមានភាសាដទៃ មួយមានទំនុកតំកើង មួយមានញាណ មួយមានអារម្មណ៍។ គាត់មិនអាចនិយាយបាន និយាយទៅកាន់ពួកគេ "សន្តិភាពអស់កល្ប។" គាត់មិនអាចនិយាយជាមួយពួកគេបានទេ "ការកំណត់ទុកជាមុន។" គាត់មិនអាចនិយាយជាមួយពួកគេបានទេ ពួកគេជាទារក។ ពួកគេទាំងអស់គ្នាត្រូវតែ—ត្រូវមានអារម្មណ៍អ្វីមួយ ឬឃើញអ្វីមួយ ឬមានអារម្មណ៍គួរឱ្យអស់សំណើច និង ឬអ្វីមួយនៅជុំវិញពួកគេ ភស្តុតាងមួយចំនួន។

60 ប៉ុន្តែខ្ញុំជឿថា ពេលគាត់និយាយទៅកាន់អេភេសូរ គាត់អាចនិយាយនៅលើ "ព្រះបានកំណត់យើងទុកជាមុនជាកូនប្រុសកូនស្រី ហើយបានយកយើងមកជាកូនក្នុងព្រះយេស៊ូវគ្រីស្ទ មុនកំណើតពិភពលោក។" មើលនោះនែ។ ខ្ញុំអើយ!

61 មើលគាត់មកក្នុងសៀវភៅរ៉ូម ជាដើម។ ពួកគេធំឡើង។ អូ ពួកគេបាននិយាយដោយភាសាដទៃ ពិតហើយ ពួកគេមានទីសំគាល់ផ្សេងទៀតនៃព្រះវិញ្ញាណបរិសុទ្ធក្នុងចំណោមពួកគេ។ ប៉ុន្តែពួកគេមិនបានបង្កើតគោលលទ្ធិ និងញាណ និងការរំជើបរំជួល និងអារម្មណ៍គួរឱ្យអស់សំណើចឡើយ។

62 ប៉ុលបាននិយាយថា "អ្នក—អ្នក—អ្នកខ្លាំងមាំជាមួយវា។ ពេលដែលអ្នកគួរបង្រៀន អ្នកនៅតែជាទារក ហើយត្រូវតែមានទឹកដោះ។"

63 ឥឡូវនេះ នោះជាអ្វីដែលខ្ញុំតែងតែព្យាយាមតម្កល់ឆាងឧបោសថនេះឲ្យក្លាយទៅជា មិនមែនជាក្រុមទារកនោះទេ។ ចូរយើងធំឡើង។ ឈរនៅលើផ្លូវ។ អូ ខ្ញុំអើយ! ហ្នឹងហើយ។

64 ដូច្នេះ ប៉ុលចុះទៅទីនោះ ជាមុនសិន ដើម្បីមើលថាតើបទពិសោធន៍របស់គាត់ត្រូវនឹងគម្ពីររបស់ព្រះឬអត់។

65 អូ វានឹងមិនអស្ចារ្យទេ នៅថ្ងៃនេះ ប្រសិនបើមនុស្សបានធ្វើបែបនោះម្តងទៀត បើយើងធ្វើឲ្យបទពិសោធន៍របស់យើងត្រូវនឹងព្រះគម្ពីររបស់ព្រះ? ប្រសិនបើវាមិនដូច្នោះទេ បទពិសោធន៍របស់យើងគឺខុស។ វាមិនបញ្ចេញពន្លឺនៅក្នុងយូរីមធូមមីមទេ។ ប្រសិនបើវាភ្លឺនៅក្នុងនោះ អាម៉ែន ដឹងថាអ្នកបានទទួលវាហើយ។ ប៉ុន្តែ

ប្រសិនបើវាមិនភ្លឺ ខ្លះ...ខ្ញុំមិនខ្វល់ថាវាហាក់ដូចជាល្អប៉ុណ្ណាទេ វាមើលទៅដូចជាត្រូវប៉ុណ្ណានោះទេ ប្រសិនបើភ្លើងទាំងនោះមិនបានភ្លឺលើយ៉ូរីមធូមមីម នោះគឺខុស។

66 ហើយមិនថាអ្នកមានបទពិសោធច្រើនប៉ុណ្ណាទេ វាហាក់ដូចជាពិតប៉ុណ្ណា ការបង្ហាញវាបែបណាទេ របៀបដែលការអប់រំរបស់វា ឬជាឧបករណ៍ដ៏អស្ចារ្យអ្វីដើម្បីឈ្នះព្រលឹងមនុស្ស ប្រសិនបើវាមិនបញ្ចេញពន្លឺនៅក្នុងព្រះបន្ទូលគឺខុស។ ត្រូវហើយ។ វាត្រូវតែតម្រង់ជួរជាមួយនឹងព្រះបន្ទូល។

67 ឥឡូវនេះ ខ្ញុំជឿលើ...មាននៅកណ្តាលផ្លូវ។ ផ្លូវ ឥឡូវនេះ ជាច្រើនលើក... ខ្ញុំធ្លាប់ទៅព្រះវិហារណាសារីន។ ព្រះអម្ចាស់ប្រទានពរដល់មនុស្សជាទីស្រឡាញ់ទាំងនោះ។ មេតូឌីស្តដែលបានញែកជាបរិសុទ្ធតាមសម័យបុរាណ គឺជាអ្វីដែលពួកគេមាន ព្រះវិហារនៃព្រះ ណាសារីន ភៀលគ្រីមហូលីណេស និងព្រះវិហារបរិសុទ្ធចាស់ៗល្អៗជាច្រើន។ ហើយពួកគេធ្លាប់ច្រៀងចម្រៀងមួយបទ៖

ខ្ញុំដើរលើមហាវិថីចាស់
ប្រាប់កន្លែងណាដែលខ្ញុំទៅ
ខ្ញុំចង់ធ្វើជាគ្រិស្ទានសម័យដើម ព្រះអម្ចាស់អើយ
ជាងអ្វីដែលខ្ញុំដឹង។

68 ល្អ។ អស្ចារ្យណាស់។ ហើយបន្ទាប់មកពួកគេធ្លាប់និយាយអំពីផ្លូវហាយវេនៃភាពបរិសុទ្ធ។ ឥឡូវនេះ បើអ្នកអានវាចេញពីអេសាយ ជំពូកទី ៣៥។ ឥឡូវនេះ ប្រសិនបើអ្នកកត់សម្គាល់ គាត់បាននិយាយថា "វានឹងមានផ្លូវមួយ *និងផ្លូវមួយ*។"

69 ឥឡូវនេះ *និង*ជាការភ្ជាប់។ ឃើញទេ? ផ្លូវធំ វាមិនមែនជាផ្លូវធំដ៏បរិសុទ្ធទេ។ "វានឹងក្លាយជាផ្លូវធំ *និង*ជាផ្លូវមួយ ហើយវានឹងត្រូវហៅថា 'ផ្លូវនៃសេចក្តីបរិសុទ្ធ'" មិនមែនជាផ្លូវនៃសេចក្តីបរិសុទ្ធទេ។ "ផ្លូវនៃភាពបរិសុទ្ធ!" ហើយទ្រូងនៃផ្លូវគឺពាក់កណ្តាលផ្លូវ។ *សង់បែបនេះ*ដើម្បីឲ្យទឹកលាងសម្អាតសំរាមទាំងសងខាង រក្សាផ្លូវឲ្យស្អាត។ អ្នកមិន អ្នកមានភក់នៅលើផ្លូវរបស់អ្នកគ្រប់ពេល ប្រសិនបើវាមិនត្រូវបានសាងសង់ត្រឹមត្រូវ។ "ទ្រូងផ្លូវ" គឺជាកណ្តាលផ្លូវ។

70 ឥឡូវនេះ នៅផ្នែក*ខាងនេះ* នៅពេលដែលមនុស្សបានប្រែចិត្ត គំនិតរបស់ពួកគេត្រូវបានតាំងចិត្តលើព្រះគ្រីស្ទ។ ហើយប្រសិនបើពួកគេគ្រាន់តែជាអ្នកប្រាជ្ញតិចតួច ហើយមិននៅក្រោមការអធិស្ឋានទេ នោះពួកគេនឹងត្រជាក់ខ្លាំង និងរឹង និង

តែលតោល និងព្រងើយកណ្តើយ។ ហើយគេនឹងភ័យបន្តិច បើអ្នកមិនមើល ពួកគេនឹងព្រៃផ្សៃទាំងស្រុង នៅផ្នែក*ខាងនេះ* ឃើញទេ ពួកគេចូលទៅក្នុងអារម្មណ៍និងអ្វីៗគ្រប់យ៉ាង។

71 ឥឡូវនេះ ប៉ុន្តែ ក្រុមជំនុំពិត គឺជាដំណឹងល្អដ៏ពិតប្រាកដមួយ នៅកណ្តាលផ្លូវ។ វាមិនត្រជាក់និងស្អិតទេ ហើយក៏មិនមែនជាការនិយមជ្រុលដែរ។ វាជាដំណឹងល្អដ៏ចំណាស់ ដ៏កក់ក្តៅ សេចក្តីស្រឡាញ់ពេញបេះដូងរបស់ព្រះទៅចំកណ្តាលនៃផ្លូវ ស្រែកហៅពីភាគីទាំងសងខាង។ ត្រូវហើយ។ ឥឡូវនេះនោះជាអ្វី...ហើយតើអ្នកនឹងទទួលបានក្រុមជំនុំដោយរបៀបណា? ចេញពីព្រះបន្ទូលគឺយ៉ូរីម ធូមមីម។

72 ឥឡូវនេះ ប៉ុលចង់យកក្រុមជំនុំនេះនៅចំកណ្តាលផ្លូវ ដូច្នេះ គាត់បានទៅសិក្សាគម្ពីរបីឆ្នាំដែលគាត់បានដឹង។ ដូច្នេះ ប៉ុលបានសរសេរផ្នែកធំជាងនៃគម្ពីរសញ្ញាថ្មីនេះ។ ព្រះបានឲ្យគាត់ធ្វើដូច្នេះ ពីព្រោះវាឈានដល់សម័យសាសន៍ដទៃ។ ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ជាសៀវភៅដំណឹងល្អទាំងបួន ពួកគេជាសាសន៍យូដា។ ប៉ុន្តែប៉ុលបានសរសេរសំបុត្រភាគច្រើន។

73 សូមកត់សម្គាល់ ឥឡូវនេះ យើងនឹងចាប់ផ្តើមទទួលបានសាវតានេះឥឡូវនេះ ជាកន្លែងដែលគាត់នៅ សរសេរវា ពីក្នុងគុក។ ហើយគាត់មានបទពិសោធន៍ទាំងអស់នេះ។ ប៉ុន្តែ ជាដំបូង បទពិសោធន៍នេះត្រូវបានបញ្ជាក់ជាមុនសិន ហើយនេះគឺជាលិខិតសំខាន់របស់គាត់ទៅកាន់វា។ នេះជាលិខិតសំខាន់របស់គាត់។ រ៉ូម និងអេភេសូរ ជាដើម មានកន្លែងរបស់ពួកគេ ប៉ុន្តែនេះគឺជាលិខិតសំខាន់។

74 ឥឡូវនេះ ជំពូកទី១ទាំងមូល*កំពុង*លើកដំកើងព្រះយេស៊ូវ ហើយបំបែកទ្រង់ពីការធ្វើជាហោរា។ នោះជាប្រធានបទទាំងមូលឥឡូវនេះ។ ខ្ញុំនឹងព្យាយាមទៅដល់វាឱ្យលឿនតាមដែលអាចធ្វើបាន ដូច្នេះយើងនឹងមិននៅយូរពេកទេ។ ប្រធានបទទាំងមូល*គឺ*បំបែកជំពូកថ្មី...ថ្មី...ជំពូកទី១ *គឺ*ញែកព្រះយេស៊ូវចេញពីហោរាណាមួយ ឬច្បាប់ណាមួយ ឬផ្សេងទៀត ហើយបង្ហាញថាតើព្រះយេស៊ូវជានរណា។ ឥឡូវនេះសូមមើល "ព្រះ។" យើងចាប់ផ្តើមពាក្យដំបូង "ព្រះ។"

ឯព្រះ ដែល...*ពីដើម*...

*ពីដើម*មានន័យថា "ផ្លូវត្រឡប់មកក្រោយវិញ" ពេលវេលាត្រឡប់ក្រោយវិញ។

...កាលពីដើមទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោ ដោយពួកហោរា ជាច្រើនដងច្រើនបែប

75 ឥឡូវនេះ ឃើញទេ "ព្រះជាម្ចាស់ ពីដើម ពីពេលមុន ទ្រង់មានបន្ទូលទៅកាន់បុព្វបុរសដោយពួកហោរា។" នោះហើយជារបៀបដែលទ្រង់ត្រូវផ្តល់សាររបស់ទ្រង់តាមរយៈហោរារបស់ទ្រង់។

76 ព្រះនឹងចាត់ហោរារបស់ទ្រង់ដូចជា អេលីយ៉ា យេរេមា អេសាយ។ ហើយប្រសិនបើអ្នកនឹងកត់សម្គាល់ មិនដែលមានក្នុងប្រវត្តិសាស្ត្រពិភពលោក ដែលថាព្រះវិហារបង្កើតហោរាម្នាក់។ ស្វែងរកវានៅក្នុងគម្ពីរសញ្ញាចាស់ គម្ពីរសញ្ញាថ្មី ឬនៅក្នុងថ្ងៃនេះ នៅថ្ងៃចុងក្រោយ។ សូមបង្ហាញខ្ញុំពីហោរាណាមួយត្រូវបានលើកឡើងពីក្រុមជំនុំនៅថ្ងៃចុងក្រោយ។ បង្ហាញខ្ញុំមួយដែលធ្លាប់មាន ចេញមក។ ហើយបង្ហាញខ្ញុំពេលមួយថាហោរាម្នាក់ជា អ្នកបម្រើពិតរបស់ព្រះ ថាប្រព័ន្ធសាសនានៃពិភពលោកមិនបានថ្កោលទោសគាត់ទេ។

77 គ្រាន់តែគិតទៅ។ យេរេមា អេសាយ ទាំងអស់ចុះក្រោម តាមរយៈគម្ពីរសញ្ញាចាស់ ពួកគេថ្កោលទោសគាត់។ ព្រះយេស៊ូវមានព្រះបន្ទូលថា "អ្នកតុបតែងផ្នូររបស់ហោរា ហើយធ្វើអោយវាមានពណ៌ស ហើយអ្នកដាក់វានៅទីនោះ។" ត្រូវហើយ។

78 ក្រុមជំនុំបន្តវាបែបនោះ។ សូមមើលលោកជាតទ្រឹក។ អ្នកកាន់សាសនាកាតូលិកទាមទារចាប់គាត់។ គាត់មិនមែនជាកាតូលិកជាងខ្ញុំទេ។ ត្រូវហើយ។ ប៉ុន្តែគឺអ្នកបានទាមទារគាត់។

79 សូមមើលលោកហ្វ្រេនស៊ីនៃអាស៊ីស៊ី។ ទាមទារចាប់គាត់។ គាត់មិនមែនជាកាតូលិកជាងខ្ញុំទេ។

80 សូមមើល ចូននៃអាក។ អ្នកបានដុតនាងចោល ក្នុងនាមជាមេធ្មប់ ព្រោះនាងបានឃើញការនិមិត្ត ហើយជាវិញ្ញាណ។ ដុតនាងដូចស្មេក។ ស្ត្រីនោះស្រែកសុំក្តីមេត្តា ហើយគេដុតនាងចោល។ ប្រហែលមួយរយឆ្នាំក្រោយមក ពួកគេបានរកឃើញថានាងគឺជាហោរាស្រី។ នាងជាអ្នកបំរើរបស់ព្រះ។ អូ! ត្រូវបណ្តាសារហើយអ្នកមានទោសយ៉ាងធំ៖ អ្នកបានជីកសាកសពសង្ឃហើយបោះចោលក្នុងទន្លេ។

81 "អ្នកតែងលម្អផ្នូររបស់ហោរា ហើយដាក់ក្នុងទីនោះ។" ត្រូវហើយ។ ប្រព័ន្ធ

សាសនាមិនដែលបង្កើតមនុស្សរបស់ព្រះទេ មិនដែលមានសោះ មិនមានទោះថ្ងៃនេះ ហើយមិនដែលនឹងមានដែរ។ សាសនាដែលរៀបចំមិនដែលជាប្រធានបទរបស់ព្រះទេ។

82 ព្រះវិហារដែលបានរៀបចំចាស់ជាងគេនៅលើពិភពលោកគឺព្រះវិហារកាតូលិក លូធើ ទីពីរ បន្ទាប់មកមកហ្សីងលី បន្ទាប់ពីហ្សីងលីមក កាល់វីន កាលវីន លើ អង់គ្លីខិន អង់គ្លីខិនឡើងមកបន្ទាប់សាក់សុន រួចព្រះវិហារអង់គ្លីខិន និងស្តេចហេនរីទីប្រាំបី នៅពេលដែលគាត់បានតវ៉ា ជាដើម និងចុះទៅវេសលីមេតូឌីស្ត និងណាសារីន ភៀលគ្រីមហូលីណេស ហើយចុះទៅចុងក្រោយ គឺពេនទីកុស្ត ដែលរៀបចំទាំងអស់។ ហើយព្រះគម្ពីរបង្រៀនយ៉ាងច្បាស់លាស់ថាព្រះវិហារកាតូលិកគឺ គឺ—ជាស្ត្រីអាក្រក់ម្នាក់ ហើយព្រះវិហារប្រូតេស្តង់និងអង្គការរបស់ពួកគេ គឺជាកូនស្រីរបស់នាង វិវរណៈ ១៧។ នោះពិតជាត្រឹមត្រូវ។ ដូច្នេះពួកគេ...

83 មិនមែនប្រជាជនទេ ឥឡូវនេះ។ មានសេចក្តីល្អនៅក្នុងពួកជំនុំទាំងអស់បរិសុទ្ធ មនុស្សដែលបានសង្គ្រោះ។ ប៉ុន្តែ ព្រះមិនហៅរាស្ត្ររបស់ទ្រង់តាមអង្គការមួយទេ។ ទ្រង់ហៅពួកគេថាជាបុគ្គល។ ព្រះដោះស្រាយជាមួយបុគ្គលម្នាក់ៗ មិនថាអ្នកជាមេតូឌីស្ត បាបទីស្ត ប្រូតេស្តង់ និងកាតូលិក ឬអ្នកជាអ្វីទេ។ ព្រះជាម្ចាស់ មុនកំណើតពិភពលោក បានស្គាល់អ្នក ហើយកំណត់ទុកអ្នកទៅកាន់ជីវិតអស់កល្បជានិច្ច ឬអ្នកត្រូវបានកំណត់ទុកជាមុនចំពោះការបាត់បង់អស់កល្បជានិច្ច។ អត់ទេ...

84 ទ្រង់មិនព្រមឲ្យអ្នកត្រូវវិនាសទេ អ្នកគឺត្រូវវិនាស។ ប៉ុន្តែ ទ្រង់ជាព្រះគ្មានដែនកំណត់ ទ្រង់ជ្រាបពីទីបញ្ចប់តាំងពីដើមមក ឬទ្រង់មិនមែនជាព្រះ។ ដូច្នេះព្រះយេស៊ូវមិនដែលយាងមកផែនដីដើម្បីនិយាយថា "អញ្ចឹង ខ្ញុំនឹងមើលថាតើអ្នកណាម្នាក់មានចិត្តមេត្តាដែរឬទេ...បើខ្ញុំធ្វើហើយស្លាប់ គេប្រហែលជាគិតថា 'អញ្ចឹងខ្ញុំ...' វានឹង—វានឹងបញ្ចុះបញ្ចូលបេះដូងរបស់ពួកគេ ហើយពួកគេនឹង..." ព្រះមិនបើកជំនួញរបស់ទ្រង់បែបនោះទេ។

85 ព្រះយេស៊ូវយាងមកក្នុងគោលបំណងជាក់លាក់មួយ នោះគឺដើម្បីសង្គ្រោះអស់អ្នកដែលព្រះ មុនកំណើតពិភពលោកបានដឹងថានឹងបានសង្គ្រោះ។ ទ្រង់មានបន្ទូលដូច្នេះ។ ត្រឹមត្រូវហើយ។ ដូច្នេះអ្នកគឺជា..."វាមិនមែនជាអ្នកដែលមានឆន្ទៈ

ឬអ្នកដែលរត់ វាគឺជាព្រះដែលបង្ហាញសេចក្តីមេត្តាករុណា។" ប៉ុលបាននិយាយដូច្នេះ។ មនុស្សដូចគ្នានៅទីនេះ។

86 គាត់និយាយ "នោះហើយជាមូលហេតុដែលព្រះអាចនិយាយបាន មុនពេលអេសាវ ឬយ៉ាកុបកើតមក ទ្រង់មានបន្ទូលថា "អញស្រឡាញ់ម្នាក់ហើយស្អប់ម្នាក់ទៀត។" មុនពេលក្មេងប្រុសទាំងពីរកើតមក ព្រះទ្រង់ជ្រាបថាអេសាវគឺជាមនុស្សអៀនខ្មាស ហើយទ្រង់ដឹងថាយ៉ាកុបជាកូន...គាត់ស្រឡាញ់សិទ្ធិកំណើតបងច្បងរបស់គាត់។ ដូច្នេះ ទ្រង់បានជ្រាបថា មុនពេលពិភពលោកត្រូវបានបង្កើតឡើង អំពីវា។ ឥឡូវនេះ យើងនឹងស្វែងយល់ក្នុងមួយនាទីថា តើនរណាជាអ្នកនោះបានដឹង។ ជំពូកនេះបានមានវា។

> ឯព្រះ...ដែល*ពីដើម* ទ្រង់*មានព្រះបន្ទូល...នឹងពួកឰយុកោ ដោយពួកហោរា*
>
> *នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានព្រះបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ...*

បានធ្វើអ្វី? "បានមានបន្ទូលមកយើងនៅថ្ងៃចុងក្រោយនេះ ដោយព្រះរាជបុត្រាទ្រង់។"

87 ឥឡូវនេះ តើអ្នកគិតយ៉ាងណា ថា តើអ្វីជាហោរា? តើយើងនឹងមានហោរាម្នាក់នៅថ្ងៃនេះឬ? ច្បាស់ណាស់។ តើទ្រង់នឹងនិយាយដោយយើងទេ? ប្រាកដណាស់។ ប៉ុន្តែគាត់...ហោរានៅសម័យបុរាណ គឺជាព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ ។

88 ឥឡូវនេះ ចូរនិយាយឲ្យត្រង់ទៅ ព្រោះខ្ញុំគិតថាវាមិនត្រូវសោះ។ ឥឡូវនេះគឺដូចជាសាលាថ្ងៃអាទិត្យ ដូច្នេះយើងចង់យល់ឲ្យបានច្បាស់។ ឃើញទេ?

89 សូមកត់សម្គាល់។ ចូរយើងទទួលយកព្រះវិញ្ញាណនៃព្រះ ដែលនៅក្នុងលោកម៉ូសេ យ៉ាងល្អឥតខ្ចោះ...គឺជាស្រមោលរបស់ព្រះយេស៊ូវគ្រីស្ទ ។ តួរអង្គនៃគម្ពីរសញ្ញាចាស់ទាំងអស់បង្ហាញពីឈើឆ្កាង។ ម៉ូសេដែលបានកើតមកជាកូនដ៏សមគួរលាក់ខ្លួនក្នុងគុម្ពឈើ ហើយយកចេញឆ្ងាយពីឪពុកម្តាយ ជាដើម និងជា...ទ្រង់ជាស្តេច ឬជា—អ្នកដឹកនាំ អ្នកផ្តល់ច្បាប់ អ្នកអង្វរករ ជាសង្ឃ។ អ្វីៗទាំងអស់ដែលទ្រង់ត្រូវបានជាស្រមោលព្រះគ្រីស្ទ។

90 មើលទៅយ៉ូសែប ស្រឡាញ់ឪពុកគាត់ ស្អប់ដោយបងប្អូនគាត់ ហើយត្រូវបានលក់ជាប្រាក់ជិតសាមសិបដុំ។ បោះចូលទៅក្នុងជង្ហុក សន្មត់ថាត្រូវស្លាប់ បានយកចេញមកវិញ។ នៅក្នុងការបៀតបៀនរបស់គាត់ បានសង្គ្រោះ ហើយអ្នកកាប់សាច់បានស្លាប់ ចោរពីរនាក់នៅឈើឆ្កាង។ ពេលគាត់ចេញមក គាត់ក៏ងើបចេញពីប្រឡាយនោះ ហើយដាក់នៅខាងស្តាំព្រះចៅផារ៉ោន ជាផ្នាំងរូបភាពដ៏ធំបំផុត...នេះ—នេះ—ប្រជាជាតិដែលវាយកម្ទេចពិភពលោកទាំងមូល។ គ្មាននរណាអាចមករកផារ៉ោនបានឡើយ លើកលែងតែពួកគេមកតាមយ៉ូសែបប៉ុណ្ណោះ ព្រះយេស៊ូវគង់នៅខាងស្តាំព្រះហស្តរបស់ព្រះជាម្ចាស់ ហើយគ្មានអ្នកណាអាចមកឯព្រះជាម្ចាស់បានឡើយ លើកលែងតែតាមរយៈព្រះគ្រិស្ត។ កាលយ៉ូសែបចាកចេញពីបល្ល័ង្កនោះហើយចាប់ផ្តើមចេញទៅ នោះមនុស្សក៏ចូលទៅមុខគាត់ទាំងស្រែកនិងផ្លុំត្រែ បន្លឺសំឡេងត្រែដោយនិយាយថា "លុតជង្គង់! យ៉ូសែបកំពុងមក។"

91 ពេលព្រះយេស៊ូវយាងមក ត្រែនឹងបន្លឺឡើង ជង្គង់នីមួយៗនឹងលុតចុះ ហើយគ្រប់អណ្តាតនឹងសារភាព។ បាទ។ ទ្រង់នៅទីនោះ។

92 ហើយពេលយ៉ូសែបបានស្លាប់ លោកបានបន្សល់ទុកនូវអនុស្សាវរីយ៍មួយដល់អ្នកដែលកំពុងរង់ចាំការរំដោះ។

93 ខ្ញុំដាក់ដៃលើឈូកចាស់ ដែលមិនយូរប៉ុន្មានទេ វាធ្វើពីសំណ។ ហើយរាងកាយរបស់គាត់ត្រូវបានគេសន្មត់ថាស្ថិតនៅ...ឆ្អឹងរបស់គាត់...បាននិយាយថា "កុំកប់ខ្ញុំនៅទីនេះ ព្រោះថ្ងៃណាមួយ ព្រះនឹងមកលេងអ្នក។" គាត់គឺជាហោរា។ "ព្រះនឹងមកលេងអ្នក។" ហើយបាននិយាយថា "ពេលអ្នកឡើងទៅឯទឹកដីសន្យា ចូរយកឆ្អឹងខ្ញុំទៅ។"

94 ជនជាតិហេព្រើរគ្រប់រូប ជាមួយនឹងការវាយបកនិងបង្ហូរឈាម អាចមើលទៅក្នុងមឈូសនោះហើយនិយាយថា "ថ្ងៃណាមួយ យើងនឹងចេញទៅក្រៅ។"

95 ព្រះយេស៊ូវបានបន្សល់ទុកកន្លែងរំលឹកមួយ ជាផ្នូរទទេ។ ថ្ងៃណាមួយពេលយើងទៅឯផ្នូរ និងមនុស្សជាទីស្រលាញ់របស់យើង ហើយលឺថាក្តាមចាស់តូចៗពេលដែលគេនិយាយថា "ផេះទៅជាផេះ និងធូលីទៅជាធូលី និងដីទៅជាដី។" ប៉ុន្តែបងប្អូនអើយ យើងអាចមើលឆ្លងសមុទ្រ ទៅឯផ្នូរទទេ។ ថ្ងៃណាមួយ ពួកយើងនឹងចេញពីទីនេះ។ យើងទៅផ្ទះ។ ទ្រង់កំពុងមក។ អ្វីគ្រប់យ៉ាងត្រូវបានវាយបញ្ចូល។

96 សូមក្រឡេកមើលព្រះបាទដាវីឌ ដែលត្រូវបានប្រជារាស្ត្ររបស់ព្រះអង្គ
បដិសេធ ហើយត្រូវបានទម្លាក់ដោយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់។ ក្នុងនាម
ជាស្តេចក្រុងយេរូសាឡឹម ត្រូវបានប្រជាជនរបស់ព្រះអង្គបណ្តេញចេញពីក្រុង
យេរូសាឡឹម។ ពេលឡើងភ្នំអូលីវ គាត់មើលទៅក្រោយ ហើយយំ។ គាត់ត្រូវបាន
បដិសេធ។

97 ប្រាំបីរយឆ្នាំចាប់ពីពេលនោះមក ព្រះរាជបុត្រាព្រះបាទដាវីឌ ជាស្តេចក្រុង
យេរូសាឡឹម តាំងនៅលើភ្នំ ហើយយំ ព្រោះទ្រង់ត្រូវគេបដិសេធ។

98 នោះគឺជាព្រះវិញ្ញាណនៃព្រះគ្រីស្ទនៅក្នុងព្រះបាទដាវីឌ។ ទាំងអស់បាន
ទាយពីឈើឆ្កាង។ ពួកហោរានៅទីនោះបាននិយាយក្នុងព្រះនាមទ្រង់។ ពួកគេ
បានរស់នៅក្នុងព្រះនាមទ្រង់។ ពួកគេបានប្រព្រឹត្តនៅក្នុងព្រះនាមទ្រង់។ ប្រាកដ
ណាស់។ "ព្រះជាម្ចាស់នៅគ្រាដើម និងអាកប្បកិរិយាចម្រុះគ្នាបានមានបន្ទូល
ទៅកាន់ពួកឰយុកោតាមរយៈហោរា ប៉ុន្តែនៅក្នុងថ្ងៃចុងក្រោយនេះ តាមរយៈ
ព្រះរាជបុត្រារបស់ទ្រង់។"

99 ដូច្នេះ ហោរា និងមនុស្សខាងវិញ្ញាណ សព្វថ្ងៃនេះ គឺគ្រាន់តែជាការឆ្លុះបញ្ចាំង
ពីព្រះគ្រីស្ទប៉ុណ្ណោះ។ នៅទីនោះ តាមច្បាប់ដែលគេឈរ មើល។ នៅទីនេះ ពួកគេ
ឈរ សម្លឹងទៅទិសផ្សេង តាមរយៈព្រះគុណ។

100 ថានៅក្នុងហេព្រើរ១១ ជំពូកចុងក្រោយ ខ្ញុំបានឆ្ងល់ជាញឹកញាប់។ នៅក្នុង
ជំពូកចុងក្រោយ ជាផ្នែកចុងក្រោយនៃជំពូកទី១១នៃហេព្រើរ នៅពេលដែលគាត់
និយាយអំពីអ័ប្រាហាំ។ ជំពូកសេចក្តីជំនឿដ៏អស្ចារ្យ ហើយនៅទីបញ្ចប់ លោក
បានមានប្រសាសន៍ថា "ពួកគេដើរលេងដោយស្បែកចៀមនិងស្បែកពពែ ហើយ
ត្រូវបានទុគ៌ត ហើយត្រូវបានគេកាត់ជាដុំៗ។ ពួកគេដើរទៅមក គ្មានកន្លែងទៅ ត្រូវ
គេស្អប់ខ្ពើម បោះបង់ និងបៀតបៀន។ ក្នុងចំណោមអ្នកណា ពិភពលោកនេះមិន
សក្តិសមនឹងមនុស្សបែបនេះទេ។"

101 ពេលនោះប៉ុលឈរនិយាយថា "ប៉ុន្តែបើគ្មានយើង ពួកគេមិនល្អឥតខ្ចោះ
ទេ។" ដ្បិតគេមើល*រំភែ*ឈើឆ្កាង ហើយយើងមើល*តាម*ឈើឆ្កាង។ យើងមាន
ព្រះវិញ្ញាណនៃព្រះគ្រីស្ទ បន្ទាប់ពីវាបានក្លាយជាសាច់ឈាមមនុស្ស ហើយបាន
គង់នៅក្នុងចំណោមយើង។ យើងមកទីនេះដោយព្រះវិញ្ញាណបរិសុទ្ធ ដែលជា
ផែនការដ៏ប្រសើរ។

102 ហើយពេលខ្លះខ្ញុំឆ្ងល់ថាតើសាសនាគ្រីស្តរំពឹងអ្វីនៅថ្ងៃនេះ? គ្រូអធិប្បាយដែលចូលទៅក្នុងក្រុងត្រូវតែមាន...ឬព្រះវិហារថ្មីឬតំណែងថ្មីខ្លះ ហៅខ្លួនគាត់ថាជាហោរា ដើរទៅទីនោះ និយាយថា "បើគេឲ្យលុយខ្ញុំច្រើនម្ល៉េះ។ ប្រសិនបើខ្ញុំអាចមានឡានល្អបំផុត។ ប្រសិនបើពួកគេនឹង...ប្រសិនបើប្រាក់ខែរបស់ខ្ញុំនឹងត្រូវដំឡើងរៀងរាល់ប្រាំមួយខែម្តង។"

103 យើងត្រូវតែមានអ្វីដែលល្អបំផុត។ យើងត្រូវតែមានផ្ទះល្អបំផុត។ យើងត្រូវតែមានសម្លៀកបំពាក់ល្អបំផុត។ តើយើងនឹងធ្វើយ៉ាងណាពេលយើងឈរនៅចំពោះមុខបុរសដែលវង្វេងទាំងពាក់ស្បែកពពែនិងស្បែកចៀម គ្មានកន្លែងផ្តេកក្បាល ដើរនៅទីរហោស្ថាននោះ? ហើយមាននរណាម្នាក់អាចលេងសើចនឹងយើង ហើយយើងត្រៀមខ្លួនជាស្រេចដើម្បីឈប់ទៅព្រះវិហារហើយមិនត្រឡប់ទៅវិញទៀតទេ។ អ្វីដែលគ្រិស្ទានទាមទារសព្វថ្ងៃ។ យើងគួរតែខ្មាសខ្លួនឯង។

ឱព្រះជាម្ចាស់អើយ សូមអាណិតមេត្តាយើងខ្ញុំផង។

104 នៅថ្ងៃនោះ ទ្រង់មានបន្ទូលតាមរយៈហោរា ប៉ុន្តែថ្ងៃនេះតាមរយៈព្រះរាជបុត្រាទ្រង់។ នោះគឺជាពាក្យរបស់ហោរា នៅទីនោះ។ នេះគឺជាព្រះបន្ទូលរបស់ព្រះរាជបុត្រា សព្វថ្ងៃនេះ។ អូ សូមថ្វាយព្រះពរដល់ព្រះនាមព្រះអម្ចាស់!

105 ម្យ៉ាងទៀត បើអ្នកសម្លឹងមើលស្រមោលអរិជ្ញមាន អ្នកអាចនឹងមានកំហុស។ ប៉ុន្តែនេះត្រូវបានអភិវឌ្ឍ រូបភាពគឺច្បាស់។ នោះគឺដោយហោរានេះគឺដោយព្រះរាជបុត្រារបស់ទ្រង់។ នោះគឺដោយអរិជ្ញមាន នេះគឺដោយវិជ្ជមាន។ អាម៉ែន។ អ្នកមើលឃើញវាទេ? មិនមានឱកាសបាត់បង់ទេ។ វាជារឿងវិជ្ជមាន ថ្ងៃនេះតាមរយៈព្រះរាជបុត្រារបស់ទ្រង់។ អូ អស្ចារ្យណាស់!

...*ដែលទ្រង់*បាន*តម្រូវឲ្យបានគ្រងរបស់ទាំងអស់*... (អូ ខ្ញុំអើយ!)...*ទុកជាមរដក*...

106 តើវាជាអ្វី? វាជាការណាត់ជួប។ អូ ស្តាប់។ ទ្រង់ត្រូវបានតែងតាំង ព្រះគ្រីស្ទជាមរតកនៃអ្វីៗទាំងអស់។ អូ អារក្សបានដឹង ពីសួនអេដែន អ្នកឃើញទេ នៅពេលដែលអារក្សបានឮព្រះបន្ទូលនៅទីនោះ នៅថ្ងៃនោះ នៅក្នុងការជំនុំជំរះរបស់មនុស្សទាំងនោះ។ បាននិយាយថា "ដោយសារតែអ្នកមកពីធូលីដី អ្នកនឹងត្រលប់ជាដីវិញ ហើយពូជស្ត្រីនឹងកិនក្បាលពស់។" ពូជសន្យា។

107 សាតាំងបានតាមដានពូជនោះជានិច្ច។ ពេលអេបិលកើត វានិយាយថា "ហ្នឹងហើយ គឺជាគ្រាប់ពូជ។" ហើយវាបានសម្លាប់អេបិល។ កូនប្រុសរបស់វា កាអ៊ីន បានសម្លាប់អេបិល។ ហើយពេលអេបិលស្លាប់ វាបាននិយាយថា "ខ្ញុំមានគ្រាប់ពូជហើយ។" គាត់បានសម្លាប់វា។ គាត់បាននិយាយថា "ខ្ញុំទទួលបានហើយ។" ប៉ុន្តែ ការស្លាប់របស់អេបិល កំណើតរបស់សេតគឺជាការរស់ឡើងវិញម្តងទៀត។ មើលពីរខ្សែស្រាឡាយពួកគេចុះមក។

108 ខ្សែស្រាឡាយរបស់សេតនោះ វាចុះមកជាមនុស្សរាបទាប និងសុចរិត ខ្សែស្រាឡាយចុះមកតាមរយៈអេណុក ទៅលើណូអេ រហូតដល់ចុងបញ្ចប់នៃការបំផ្លិចបំផ្លាញមុនពេលទឹកជំនន់។

109 សូមក្រឡេកមើលខ្សែរបស់កាអ៊ីន ក្លាយជាមនុស្សឆ្លាត ការអប់រំ អ្នកវិទ្យាសាស្ត្រ។ គម្ពីរមិនបានចែងទេឬថា...តើព្រះយេស៊ូវទ្រង់មានបន្ទូលថា នោះ "កូនរបស់លោកិយឆ្លាតជាងកូននៃនគរទៅទៀត"? សូមក្រឡេកមើលផ្នែកខាងកាអ៊ីននៅថ្ងៃនេះ៖ ឆ្លាត មានការអប់រំ មានមន្ទិលសង្ស័យ សាសនាខ្លាំងណាស់។ សូមមើល បែបសាសនាខ្លាំងណាស់ ប៉ុន្តែអ្នកវិទ្យាសាស្ត្រ អ្នកសាងសង់ ជាមនុស្សអស្ចារ្យ។

110 យកបុរសអស្ចារ្យ។ សូមក្រឡេកមើលថូម៉ាស អេឌីសុន ដែលជាបុរសដ៏អស្ចារ្យជាច្រើន។ ក្រឡេកមើលអែងស្តែង ខួរក្បាលរបស់ពិភពលោក ដែលគេហៅសព្វថ្ងៃនេះ ខួរក្បាលរបស់ពិភពលោក។ ប៉ុន្តែយើងមិនព្យាយាមប្រើខួរក្បាលទេ។ យើងទុកឲ្យចិត្តដែលនៅក្នុងព្រះគ្រីស្ទនៅក្នុងយើង ហើយមើលទៅព្រះបន្ទូលនេះ ហើយហៅដូច្នេះ។

111 គ្រូពេទ្យ ថ្វីត្បិតតែយើងសរសើរពួកគេដោយអ្វីដែលយើងមានក៏ដោយ ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះគឺជាអ្នកសង្ស័យ និងអនាមិក។ សូមក្រឡេកមើលមនុស្សឆ្លាតនិងឆ្លាតវៃនៅថ្ងៃនេះ។ ពួកគេនៅខាងនោះ ខាងកាអ៊ីន។

112 ប៉ុន្តែមើលទៅមនុស្សស្លូតបូត។ មានការរស់ឡើងវិញរបស់អ្នកម្តងទៀត។ អូ សូមថ្វាយព្រះពរដល់ព្រះនាមព្រះអម្ចាស់! ហ្នឹងហើយ។ សូមកត់សម្គាល់។

> ...ដែលទ្រង់បានតម្រូវឲ្យបាន*គ្រងរបស់ទាំងអស់ ទុកជាមរដក ព្រមទាំងបង្កើតលោកីយ៍*

